**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករធានារ៉ាប់រងកម្ពុជា**
លេខ......០០៦........ន.ធ.ក./សណាង

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២៣

# គោលការណ៍ណែនាំ
# ស្តីពី
# បរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង, អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង, អនុក្រឹត្យលេខ ១១៣ អនក្រ. បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ប្រកាសលេខ ០៣៧ អ.ស.ហ. ប្រក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលកម្ពុជា និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការធានារ៉ាប់រង និងដើម្បីជំរុញនវានុវត្តន៍បច្ចេកវិទ្យាក្នុងវិស័យធានារ៉ាប់រង ក៏ដូចជាដើម្បីកំណត់បរិស្ថានសម្រាប់សាកល្បង បច្ចេកវិទ្យាធានារ៉ាប់រងជាមួយអតិថិជន ក្នុងលំហជាក់លាក់ និងរយៈពេលកំណត់មួយ និយ័តករធានារ៉ាប់រងកម្ពុជា (**ន.ធ.ក.**) រៀបចំគោលការណ៍ណែនាំស្តីពី “**បរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង**” ដែលកំណត់គោលដៅនៃបរិស្ថានសាកល្បង ប្រភេទបច្ចេកវិទ្យាធានារ៉ាប់រងអាចសាកល្បង និងនិតិវិធីនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតសាកល្បងក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង។

និយ័តករធានារ៉ាប់រងកម្ពុជា (**ន.ធ.ក.**) សូមចេញគោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ដូចខាងក្រោម៖



អគារលេខ ១៦៨ F (ជាន់ទី៦) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា
Building #168 F (6th Floor), St. 598, Sangkat Chraing Chamres 1,
Khan Russey Keo, Phnom Penh, Cambodia.
071 258 0896
gad@irc.gov.kh
www.irc.gov.kh

## ១. គោលដៅនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង

បរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រងមានគោលដៅជំរុញឱ្យមានការផ្ដួចផ្ដើមក្នុងការបង្កើតនវានុវត្តន៍បច្ចេកវិទ្យាក្នុងវិស័យធានារ៉ាប់រងឱ្យកាន់តែសម្បូរបែប និងអាចធ្វើការសាកល្បងក្នុងលំហជាក់លាក់និងរយៈពេលកំណត់មួយ ដើម្បី៖

ក- ជំរុញការអភិវឌ្ឍទីផ្សារធានារ៉ាប់រង

ខ- ផ្ដល់អត្ថប្រយោជន៍ដល់ដំណើរការអាជីវកម្មធានារ៉ាប់រង

គ- ជំរុញការផ្ដល់សេវាធានារ៉ាប់រងឱ្យកាន់តែមានគុណភាព ប្រសិទ្ធភាព និងបរិយាបន្នដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍឥតឈប់ឈរ និងឆាប់រហ័សនៃកំណើនសេដ្ឋកិច្ចនិងសង្គមឌីជីថល។

## ២. ប្រភេទបច្ចេកវិទ្យាធានារ៉ាប់រងដែលអាចសាកល្បង

ប្រភេទបច្ចេកវិទ្យាធានារ៉ាប់រងដែលអាចធ្វើការសាកល្បងក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រងមិនត្រូវផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និង/ឬសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ហើយត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

ក- ជាបច្ចេកវិទ្យាធានារ៉ាប់រងដែលមិនមានភាពស្រដៀងគ្នាទៅនឹងបច្ចេកវិទ្យាធានារ៉ាប់រងដែលមានស្រាប់នៅក្នុងទីផ្សារធានារ៉ាប់រងនៃព្រះរាជាណាចក្រកម្ពុជា។

ខ- ជាបច្ចេកវិទ្យាធានារ៉ាប់រងដែលមានស្រាប់នៅក្នុងទីផ្សារធានារ៉ាប់រង ប៉ុន្តែមិនទាន់ឆ្លងកាត់ ឬមិនទទួលបានជោគជ័យពីការសាកល្បងក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រងនៃប្រទេសណាមួយនៅឡើយ។

គ- ជាបច្ចេកវិទ្យាធានារ៉ាប់រងផ្សេងទៀត តាមការតម្រូវរបស់ **ន.ធ.ក.**។

## ៣. នីតិវិធីនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតសាកល្បង

បុគ្គលដែលមានបំណងសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាត មក **ន.ធ.ក.** ដោយភ្ជាប់ជាមួយនូវឯកសារតម្រូវតាមទម្រង់បែបបទដែលកំណត់ដោយអគ្គនាយកនៃ **ន.ធ.ក.**។ ដ្យាក្រាមនៃនីតិវិធីនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតសាកល្បងមានក្នុងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ។

### ៣.១. បុគ្គលដែលអាចដាក់ពាក្យស្នើសុំ

បុគ្គលដែលអាចដាក់ពាក្យស្នើសុំ (តទៅហៅថា "បុគ្គលដាក់ពាក្យស្នើសុំ") ត្រូវតែជា៖

ក- គ្រឹះស្ថានធានារ៉ាប់រង រួមមាន ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ក្រុមហ៊ុនធានារ៉ាប់រងបន្ត ក្រុមហ៊ុនជើងសាធានារ៉ាប់រង ក្រុមហ៊ុនភ្នាក់ងារ

ធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និង ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ដែលទទួលបានអាជ្ញាបណ្ណអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ-ក្រុមហ៊ុនបច្ចេកវិទ្យាប្រតិស្រុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងនាំយកនវានុវត្តន៍បច្ចេកវិទ្យាធានារ៉ាប់រងមកធ្វើការសាកល្បង។

### ៣.២. លក្ខណៈវិនិច្ឆ័យនៃបុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

ក- ត្រូវសហការជាមួយគ្រឹះស្ថានធានារ៉ាប់រង ចំពោះបុគ្គលដាក់ពាក្យស្នើសុំដូចបានកំណត់ក្នុងចំណុច ៣.១. "ខ" ខាងលើ។

ខ- ត្រូវមានប្រព័ន្ធការងារ និងធនធានមនុស្សដែលមានចំណេះដឹង សមត្ថភាព និងបទពិសោធគ្រប់គ្រាន់ក្នុងការសាកល្បង និងដាក់ឱ្យដំណើរការបច្ចេកវិទ្យាធានារ៉ាប់រង។

គ- ត្រូវកំណត់វិសាលភាពនិងលទ្ធផលរំពឹងទុកនៃការសាកល្បង និងលទ្ធផលរំពឹងទុកនៃការប្រើប្រាស់បច្ចេកវិទ្យាធានារ៉ាប់រងបន្ទាប់ពីការសាកល្បងជោគជ័យ។

ឃ-ត្រូវផ្តល់របាយការណ៍លទ្ធផលនៃការសិក្សាសមិទ្ធលទ្ធភាពនៃការសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ដោយរួមបញ្ចូលការសិក្សាអំពីហានិភ័យដែលអាចកើតឡើងក្នុងការសាកល្បង និងផែនការគ្រប់គ្រងនិងដោះស្រាយហានិភ័យទាំងនោះ។

ង- ត្រូវមានផែនការសម្រាប់ការចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ទាំងក្នុងករណីការសាកល្បងនោះជោគជ័យ និងមិនជោគជ័យ។

### ៣.៣. ការពិនិត្យ និងសម្រេចរបស់ ន.ធ.ក.

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

## ៤. កាតព្វកិច្ចក្នុងដំណាក់កាលសាកល្បង

ក្រោយពីទទួលបានការអនុញ្ញាតធ្វើការសាកល្បងក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង បុគ្គលដាក់ពាក្យស្នើសុំ ក្លាយជាបុគ្គលទទួលខុសត្រូវដាក់ឱ្យដំណើរការនិងធ្វើប្រតិបត្តិការក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង (តទៅហៅថា "បុគ្គលបរិស្ថានសាកល្បង")។ ក្នុងដំណាក់កាលសាកល្បង **ន.ធ.ក.** អាចតម្រូវឱ្យបុគ្គលបរិស្ថានសាកល្បងបំពេញកាតព្វកិច្ច ដូចខាងក្រោម៖

ក- បុគ្គលបរិស្ថានសាកល្បងត្រូវមានវិធានការពារអតិថិជនជាអាទិ៍៖

- ត្រូវផ្តល់ព័ត៌មានជូនអតិថិជនឱ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់ ដើម្បីជាមូលដ្ឋានសម្រាប់អតិថិជនក្នុងការសម្រេចចិត្ត និងត្រូវបញ្ជាក់ជូនអតិថិជនឱ្យបានច្បាស់ថា ជាការសាកល្បងក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ព្រមទាំងវិសាលភាពនៃការសាកល្បងនេះ។
- ត្រូវធានាឱ្យបានថាអតិថិជនយល់ព្រមក្នុងការប្រើប្រាស់ការសាកល្បងនវានុវត្តន៍បច្ចេកវិទ្យាធានារ៉ាប់រង។
- ត្រូវផ្សព្វផ្សាយដល់សាធារណជននូវរាល់ព័ត៌មានពាក់ព័ន្ធនឹងការសាកល្បងក្នុងបរិស្ថានសាកល្បងនវានុវត្តន៍បច្ចេកវិទ្យាធានារ៉ាប់រងជាអាទិ៍ នាមករណ៍ក្រុមហ៊ុន កាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់ការសាកល្បង។
- ត្រូវមានវិធានការក្នុងការដោះស្រាយបណ្តឹងរបស់អតិថិជន។
- ត្រូវមានផែនការទូទាត់សំណងនៃការខូចខាតដែលបណ្តាលមកពីកំហុសដែលកើតឡើងក្នុងដំណាក់កាលសាកល្បងជូនអតិថិជនដែលរងការខូចខាត។

ខ- បុគ្គលបរិស្ថានសាកល្បងត្រូវមានវិធានគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើងជាអាទិ៍៖

- ការរក្សាការសម្ងាត់នៃព័ត៌មាន និងប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រងរបស់បុគ្គលបរិស្ថានសាកល្បង (Confidentiality)។
- សុចរិតភាពនៃព័ត៌មាននិងប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង (Integrity)។
- ភាពដែលអាចប្រើប្រាស់បានរបស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង (Availability)។
- ហានិភ័យបច្ចេកវិទ្យាព័ត៌មាន (IT Risk) និងហានិភ័យសាយប័រ (Cyber Risk)។

គ- បុគ្គលបរិស្ថានសាកល្បងត្រូវគោរពគោលការណ៍ឯកជនភាពរបស់អតិថិជន និងអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាអាទិ៍៖

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ឃ- បុគ្គលបរិស្ថានសាកល្បង ត្រូវផ្តល់របាយការណ៍ជូន **ន.ធ.ក.** ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **ន.ធ.ក.**។

ង- បុគ្គលបរិស្ថានសាកល្បងត្រូវស្នើសុំការអនុញ្ញាតមក **ន.ធ.ក.** ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ ក្នុងករណីមានការកែប្រែជាសារវន្តនូវបច្ចេកវិទ្យាធានារ៉ាប់រងដែលកំពុងសាកល្បង ឬការផ្លាស់ប្តូរបុគ្គលដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវក្នុងការសាកល្បង ឬការកែប្រែផ្សេងៗទៀតដែលនាំឱ្យប៉ះពាល់ដល់ដំណើរការសាកល្បង ដោយត្រូវផ្តល់ព័ត៌មានលម្អិត និងមូលហេតុនៃការកែប្រែ។ បុគ្គលបរិស្ថានសាកល្បងនៅតែអាចបន្តសាកល្បងទៅតាមលក្ខខណ្ឌនៃការអនុញ្ញាតដែលមានស្រាប់ ក្នុងរយៈពេលដែល **ន.ធ.ក.** កំពុងពិនិត្យលើការស្នើសុំកែប្រែ។

អគ្គនាយកនៃ **ន.ធ.ក.** អាចចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងក្នុងដំណាក់កាលសាកល្បងនេះ។

## ៥. ការពន្យារយៈពេលសាកល្បង

ក្នុងករណីមានតម្រូវការពន្យារយៈពេលសាកល្បង បុគ្គលបរិស្ថានសាកល្បង អាចស្នើសុំការអនុញ្ញាតមក **ន.ធ.ក.** យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនពេលផុតសុពលភាពនៃការសាកល្បង និងត្រូវបញ្ជាក់អំពីមូលហេតុ នៃការស្នើសុំពន្យាពេល។ **ន.ធ.ក.** នឹងពិនិត្យការស្នើសុំដោយពិចារណាផ្តល់ការអនុញ្ញាតតាមករណីនីមួយៗ។

## ៦. ការដកហូតការអនុញ្ញាត

**ន.ធ.ក.** អាចដកហូតការអនុញ្ញាតពីបុគ្គលបរិស្ថានសាកល្បង ក្នុងករណីបុគ្គលបរិស្ថានសាកល្បង៖

- បរាជ័យក្នុងការកាត់បន្ថយហានិភ័យ ឬមិនអាចអនុវត្តវិធានការសុវត្ថិភាពតាមការតម្រូវ។
- ផ្តល់ព័ត៌មានមិនពិត ឬនាំឱ្យយល់ខុសឬមិនត្រឹមត្រូវ ឬបានបិទបាំងឬមិនបានបង្ហាញព័ត៌មានជាសារវន្តនៅក្នុងពាក្យស្នើសុំ។
- ប្រព្រឹត្តល្មើសច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បាត់បង់កេរ្តិ៍ឈ្មោះ។
- ស្ថិតក្នុងនីតិវិធីជម្រះបញ្ជី។
- ល្មើសលក្ខខណ្ឌតម្រូវសុវត្ថិភាពទិន្នន័យ និងការរក្សាការសម្ងាត់។
- ធ្វើអាជីវកម្មតាមបែបផែនដែលធ្វើឱ្យខូចប្រយោជន៍ដល់អតិថិជន វិនិយោគិន និងសាធារណជន។
- មិនអាចដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវកំហុសបច្ចេកទេស ចំណុចខ្សោយ ឬភាពងាយរងគ្រោះនៃបច្ចេកវិទ្យាធានារ៉ាប់រង ដែលបង្កជាការអាក់ខាននៃបច្ចេកវិទ្យា ឬជាសកម្មភាពបោកបញ្ឆោត។
- មិនអាចបន្តអនុវត្ត ឬមិនអាចអនុវត្តតាមលក្ខខណ្ឌតម្រូវ ឬសេចក្តីណែនាំរបស់ **ន.ធ.ក.**។

មុននឹងដកហូតការអនុញ្ញាត **ន.ធ.ក.** ត្រូវ៖

- ព្យួរជាបន្ទាន់នូវការសាកល្បងចំពោះអតិថិជនថ្មី។
- ជូនដំណឹងជាមុនដល់បុគ្គលបរិស្ថានសាកល្បងអំពីគោលបំណងនៃការដកហូតការអនុញ្ញាត។
- ផ្តល់ឱកាសដល់បុគ្គលបរិស្ថានសាកល្បងធ្វើការស្រាយបំភ្លឺជាមុន ចំពោះការដកហូតការអនុញ្ញាត។

ក្នុងករណី **ន.ធ.ក.** ដកហូតការអនុញ្ញាត បុគ្គលបរិស្ថានសាកល្បងត្រូវ៖

- អនុវត្តជាបន្ទាន់នូវផែនការចាកចេញ ដើម្បីបញ្ឈប់ការផ្តល់សេវាជូនអតិថិជនតាមរយៈបច្ចេកវិទ្យាធានារ៉ាប់រងដែលស្នើសុំសាកល្បង។
- ជូនដំណឹងដល់អតិថិជនអំពីការដកហូតការអនុញ្ញាតនេះ និងសិទ្ធិទទួលបានការដោះស្រាយបណ្តឹង។
- បំពេញកាតព្វកិច្ចកំណត់ដោយ **ន.ធ.ក.** ពាក់ព័ន្ធនឹងការរក្សាការសម្ងាត់ រួមបញ្ចូលទាំង ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនដែលទទួលបានក្នុងពេលសាកល្បង។
- ទូទាត់សំណងជូនអតិថិជនដែលរងការខាតបង់ហិរញ្ញវត្ថុ ដែលកើតចេញពីការសាកល្បងអនុលោមតាមវិធានការសុវត្ថិភាពរបស់បុគ្គលបរិស្ថានសាកល្បង។
- ផ្តល់ជូន **ន.ធ.ក.** នូវរបាយការណ៍អំពីវិធានការដែលបានដាក់ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលការអនុញ្ញាតត្រូវបានដកហូត។
- បំពេញលក្ខខណ្ឌតម្រូវផ្សេងទៀតតាមការកំណត់របស់ **ន.ធ.ក.**។

## ៧. ការបញ្ឈប់ និងការចាកចេញ

### ៧.១. ការបញ្ឈប់

ការសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង នឹងអាចត្រូវបានបញ្ឈប់ក្នុងករណី៖

- **ន.ធ.ក.** មិនអាចទទួលយកបាននូវលទ្ធផលនៃបរិស្ថានសាកល្បងសម្រេចបាន ដោយផ្អែកលើសេណារីយ៉ូចុងក្រោយ លទ្ធផលរំពឹងទុក និងកាលវិភាគដែលបានកំណត់។
- បុគ្គលបរិស្ថានសាកល្បង មិនអាចបំពេញលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិពាក់ព័ន្ធ។
- កំហុសនៃបច្ចេកវិទ្យាធានារ៉ាប់រងត្រូវបានរកឃើញថា បង្កហានិភ័យដល់អតិថិជន ឬប្រព័ន្ធហិរញ្ញវត្ថុលើសពីអត្ថប្រយោជន៍នៃបច្ចេកវិទ្យាធានារ៉ាប់រង ហើយបុគ្គលបរិស្ថានសាកល្បងទទួលស្គាល់ថា កំហុសនេះមិនអាចដោះស្រាយបានក្នុងរយៈពេលនៃការសាកល្បង។
- បុគ្គលបរិស្ថានសាកល្បង ល្មើសនឹងលក្ខខណ្ឌណាមួយដែលបានកំណត់ក្នុងរយៈពេលសាកល្បង។
- បុគ្គលបរិស្ថានសាកល្បង ស្នើសុំបញ្ឈប់បរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង។

### ៧.២. ការចាកចេញ

ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទផុតសុពលភាពនៃការសាកល្បង បុគ្គលបរិស្ថានសាកល្បង ត្រូវស្នើសុំការអនុញ្ញាតចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រងមក **ន.ធ.គ.** និងត្រូវភ្ជាប់របាយការណ៍អំពី៖

- លទ្ធផលនៃការសាកល្បង ធៀបនឹងលទ្ធផលដែលបានរំពឹងទុក។
- ការដោះស្រាយបណ្ដឹងរបស់អតិថិជន ឬការដោះស្រាយសំណងជូនអតិថិជន(ប្រសិនបើមាន)។
- ចំណេះដឹងសំខាន់ៗ ដែលទទួលបានក្រោយពីការសាកល្បង។
- ផែនការសម្រាប់ដាក់ឱ្យប្រើបច្ចេកវិទ្យាធានារ៉ាប់រងក្នុងកម្រិតទូលំទូលាយក្រោយពីការសាកល្បងក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងករណីការសាកល្បងទទួលបានជោគជ័យ។

ក្នុងករណីបច្ចេកវិទ្យាធានារ៉ាប់រងក្នុងបរិស្ថានសាកល្បងទទួលជោគជ័យមុនពេលបញ្ចប់រយៈពេលសាកល្បង បុគ្គលបរិស្ថានសាកល្បង អាចស្នើសុំការអនុញ្ញាតចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ដោយផ្ដល់របាយការណ៍ខាងលើ និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- **ន.ធ.គ.** បានយល់ឃើញថា អាចទទួលយកបាននូវលទ្ធផលដែលបរិស្ថានបច្ចេកវិទ្យាធានារ៉ាប់រងសម្រេចបាន ធៀបនឹងលទ្ធផលរំពឹងទុក។
- បុគ្គលបរិស្ថានសាកល្បងបំពេញតាមលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិពាក់ព័ន្ធ។

**ន.ធ.គ.** នឹងធ្វើការសម្រេចលើការស្នើសុំអនុញ្ញាតចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង និងប្រើប្រាស់បច្ចេកវិទ្យាធានារ៉ាប់រងកម្រិតទូលំទូលាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទទទួលសំណុំឯកសារគ្រប់គ្រាន់។

### ៧.៣. ភារកិច្ច

មុនពេលចាកចេញ ឬបញ្ចប់បរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង បុគ្គលបរិស្ថានសាកល្បងត្រូវធានាថា រាល់កាតព្វកិច្ចរបស់ខ្លួនចំពោះអតិថិជនពាក់ព័ន្ធនឹងបច្ចេកវិទ្យាធានារ៉ាប់រងដែលដំណើរការសាកល្បង ត្រូវបានបំពេញ និង/ឬដោះស្រាយបានពេញលេញ ដោយបុគ្គលបរិស្ថានសាកល្បងត្រូវ៖

- អនុវត្តផែនការចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង ព្រមទាំងផ្ដល់របាយការណ៍លទ្ធផលនៃការសាកល្បង ធៀបនឹងលទ្ធផលដែលបានរំពឹងទុក
- បញ្ឈប់ការផ្ដល់សេវាកម្មបច្ចេកវិទ្យាធានារ៉ាប់រងទៅកាន់អតិថិជនថ្មី និងបញ្ឈប់ការផ្ដល់សេវាកម្មបន្ថែមទៅកាន់អតិថិជនដែលមានស្រាប់
- ជូនដំណឹងទៅកាន់អតិថិជនឱ្យបានដឹងមុនពីការចាកចេញ ឬបញ្ឈប់ការសាកល្បង និងត្រូវធានា

ថារាល់កាតព្វកិច្ចរបស់ខ្លួនចំពោះអតិថិជនក្រោមការសាកល្បង ត្រូវបានបំពេញ និង/ ឬដោះស្រាយបានពេញលេញ មុនពេលចាកចេញពី ឬបញ្ចប់ដំណើរការសាកល្បង។

## ៨. កម្រៃ

ក្រុមហ៊ុនធានារ៉ាប់រង/ក្រុមហ៊ុនបច្ចេកវិទ្យាប្រតិស្រុតត្រូវបង់កម្រៃសេវារដ្ឋបាលដូចខាងក្រោម÷

- សេវាពិនិត្យសំណុំលិខិតសំណើសុំការអនុញ្ញាតបញ្ចូលបច្ចេកវិទ្យាធានារ៉ាប់រងទៅក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង **៥០០ ០០០ (ប្រាំរយពាន់)** រៀល
- សេវាអនុញ្ញាតដាក់បញ្ចូលបច្ចេកវិទ្យាធានារ៉ាប់រងទៅក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង **១ ០០០ ០០០ (មួយលាន)** រៀល
- សេវាពិនិត្យសំណើសុំការអនុញ្ញាតពន្យារការសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រងចូលក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង **៥០០ ០០០ (ប្រាំរយពាន់)** រៀល
- សេវាពិនិត្យសំណើសុំការអនុញ្ញាតកែប្រែផ្សេងៗលើបច្ចេកវិទ្យាធានារ៉ាប់រងនៅក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង **៥០០ ០០០ (ប្រាំរយពាន់)** រៀល។

រាល់កម្រៃសេវារដ្ឋបាល ត្រូវបង់ចូលគណនីរបស់ **ន.ធ.ក.**។ កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារអនុលោមតាមខ្លឹមសារនៃគោលការណ៍ណែនាំនេះ មិនត្រូវបានប្រគល់ឱ្យក្រុមហ៊ុនធានារ៉ាប់រងវិញឡើយ ទោះបីជាការស្នើសុំត្រូវបដិសេធក៏ដោយ។

## ៩. អនុគ្រោះកម្មបទប្បញ្ញត្តិ

ដើម្បីជំរុញឱ្យមាននវានុវត្តន៍បច្ចេកវិទ្យាធានារ៉ាប់រង **ន.ធ.ក.** នឹងពិចារណាបន្ធូរបន្ថយ ឬលើកលែងលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិ ដែលអាចក្នុងទម្រង់ជាការលើកលែងជាលក្ខណៈទូលំទូលាយ ឬជាការលើកលែងជាក់លាក់តាមករណីជាក់ស្តែងនីមួយៗ សម្រាប់ការស្នើសុំ ការបញ្ឈប់ ឬចាកចេញ និងកាតព្វកិច្ចផ្សេងៗ ដោយអាស្រ័យលើប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រងដែលជាកម្មវត្ថុនៃការសាកល្បង។

បន្ទាប់ពីការសាកល្បងទទួលបានជោគជ័យ និងចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង បុគ្គលបរិស្ថានសាកល្បង ត្រូវគោរពតាមលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិពាក់ព័ន្ធឱ្យបានពេញលេញ។

## ១០. ការអនុវត្តវិធានការផ្សេងទៀត

បន្ថែមពីការដកហូតការអនុញ្ញាត វិធានការផ្សេងទៀតដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ អាចត្រូវបានអនុវត្តចំពោះបុគ្គលបរិស្ថានសាកល្បង ក្នុងករណីបុគ្គលបរិស្ថានសាកល្បងបានធ្វើសកម្មភាពដូចខាងក្រោម៖

ក- លើ្មសគោលការណ៍ស្គាល់អតិថិជន។

ខ- លើ្មសគោលការណ៍ឯកជនភាពរបស់អតិថិជន។

គ- ជំរុញឱ្យមានការលក់ផលិតផល ឬសេវាកម្មខុសច្បាប់ ឬបោកបញ្ឆោត។

ឃ- ជំរុញឱ្យមានការលក់ផលិតផល ឬសេវាកម្មដោយផ្អែកលើការផ្តល់យោបល់ដែលនាំឱ្យយល់ខុស។

ង- លើ្មសបទប្បញ្ញត្តិពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ច- បង្កើតឱ្យមានហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ។

ឆ- រំលោភបំពានកម្មសិទ្ធិបញ្ញា។

**១១. អវសានប្បញ្ញត្តិ**

គោលការណ៍ណែនាំនេះមានអនុភាពអនុវត្តជំនួសគោលការណ៍ណែនាំលេខ ០០២ ន.ព.ក./សណន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង។

## ឧបសម្ព័ន្ធស្តីពី ដំណើរការនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង

